# សេចក្តីប្រកាសព័ត៌មានរួម

## ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី

**"គម្រោងសម្រាប់ជួយដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការត្រួតពិនិត្យការបំពុលបរិស្ថានតាមរយៈការអភិវឌ្ឍសមត្ថភាពនៃក្រសួងបរិស្ថាន"**

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងបរិស្ថាន (MOE) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ដែលមានការិយាល័យនៅប្រទេសកម្ពុជា បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ***«គម្រោងសម្រាប់ជួយដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការត្រួតពិនិត្យការបំពុលបរិស្ថានតាមរយៈការអភិវឌ្ឍសមត្ថភាពនៃក្រសួងបរិស្ថាន»*** ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធិភាពនៃការអនុវត្តការងារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងត្រួតពិនិត្យការបំពុលបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គម្រោងសហប្រតិបត្តិការបច្ចេកទេសនេះ ត្រូវបានរៀបចំឡើងរួមគ្នាដោយក្រសួងបរិស្ថាន និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន សម្រាប់ជួយដោះស្រាយក្នុងរយៈពេល៣ឆ្នាំកន្លះខាងមុខនេះនូវតម្រូវការផ្នែកសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេសរបស់ក្រសួងបរិស្ថាន ដើម្បីឱ្យអនុវត្តបេសកកម្មរបស់ខ្លួនក្នុងការធានានូវកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ លទ្ធផលរំពឹងទុករបស់គម្រោងនេះគឺ (i) ការពង្រឹងសមត្ថភាពរបស់អគ្គនាយកដ្ឋានគាំពារបរិស្ថាន (GDEP) ដើម្បីសម្រេចបាននូវភារកិច្ចរបស់ខ្លួន និង (ii) ការបង្កើត ការកែលម្អ និងការចែករំលែកទៅដល់អ្នកពាក់ព័ន្ធនូវឯកសារច្បាប់ បច្ចេកទេស និងនីតិវិធីនានាពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការត្រួតពិនិត្យការបំពុលបរិស្ថាន។

រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដើម្បីសម្រេចឱ្យបាននូវគោលដៅជាយុទ្ធសាស្ត្រនៃកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាពរបស់អង្គការសហប្រជាជាតិ។ ការធ្វើកំណែទម្រង់ស្ថាប័ន ជាមួយនឹងការត្រួតពិនិត្យកែសម្រួលឡើងវិញនូវឯកសារច្បាប់ និងបទដ្ឋានគតិយុត្តនានា គឺបង្ហាញឱ្យឃើញនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងវិស័យដ៏មានសារសំខាន់នេះ ដែលនាំឱ្យមានការកំណត់នូវបញ្ហាប្រឈម និងឱកាសថ្មីៗ និងឈានទៅដល់ការរៀបចំឱ្យមានគម្រោងនេះឡើង ដែលត្រូវបានគាំទ្រដោយទីភ្នាក់ងារ JICA។

តាមការរំពឹងទុក គម្រោងនេះនឹងចាប់ផ្តើមដំណើរការជាផ្លូវការនៅពាក់កណ្តាលឆ្នាំនេះ ហើយក៏ឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលជប៉ុន ក្នុងការបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលើកកម្ពស់កិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិតាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការត្រួតពិនិត្យការបំពុលបរិស្ថាននៅព្រះរាជាណាចក្រកម្ពុជា។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងតាមរយៈ៖**

ក្រសួងបរិស្ថាន: **ឯកឧត្តម សៅ សុភាព** ទីប្រឹក្សា និងជានាយខុទ្ទកាល័យ តាមរយៈអ៊ីម៉ែល saosopheap@yahoo.com ឬតាយរយៈទូរស័ព្ទលេខ 012 971 222

JICA នៃប្រទេសកម្ពុជា: **លោកស្រី ជីន គីមហ៊ាង** មន្ត្រីកម្មវិធីផ្នែកទំនាក់ទំនងសាធារណៈ និងកិច្ចការបណ្តុះបណ្តាល តាមរយៈអ៊ីម៉ែល: ChinKimheang.CM.2@jica.go.jp ឬតាមរយៈ ទូរស័ព្ទលេខ: 023 211 673/ 012 851 444